ផ្សារមូលបត្រកម្ពុជា

CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃពុធ ៣រោច ខែបឋមាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០២០

## សេចក្តីជូនដំណឹង

## ក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី គ្រងជ័យលាភីឈ្មួញជើងសារមូលបត្រឆ្នើមបីត្រីមាសជាប់គ្នា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា **(ផ.ម.ក.)** មានកិត្តិយសសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា ជ័យលាភីឈ្មួញជើងសារមូលបត្រឆ្នើម សម្រាប់ត្រីមាសទី២ ឆ្នាំ២០២០ គឺ **ក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី**។ នេះជាត្រីមាសទីបីហើយ ដែលក្រុមហ៊ុនមូលបត្រមួយនេះបានឈ្នះក្នុងកម្មវិធីនេះ ដោយទទួលបានពិន្ទុខ្ពស់ជាងគេក្នុងចំណោមឈ្មួញជើងសារមូលបត្រទាំង ១០ ដែលជាសមាជិករបស់ **ផ.ម.ក.** ដែលការវាយតម្លៃនេះគឺផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួន ៣ គឺ ទំហំជួញដូរមូលត្រសរុបរបស់អតិថិជន ចំនួនគណនីជួញដូរដែលបានបើកថ្មី និងការប្រើប្រាស់ប្រព័ន្ធជួញដូរចល័ត (MTS)របស់អតិថិជន។

នៅក្នុងត្រីមាសទី២ ឆ្នាំ២០២០ នេះ ទំហំជួញដូរមូលបត្រសរុបរបស់អតិថិជនក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី មានចំនួន ១០៦,៩៣ ប៊ីលានរៀល ពោលគឺស្មើនឹងប្រមាណ៥០% នៃទំហំជួញដូរសរុបរបស់ភាគហ៊ុននិងសញ្ញាបណ្ណបំណុលបញ្ចូលគ្នា។ ទន្ទឹមនឹងនេះ ៨៤%នៃចំនួនគណនីជួញដូរទាំងអស់ដែលបានបើកថ្មីជាចំណែករបស់ក្រុមហ៊ុននេះផងដែរ។ ទំហំជួញដូរសរុបរបស់អតិថិជនក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី តាមរយៈប្រព័ន្ធ MTS មានចំនួន ៩៨,២២ ប៊ីលានរៀល ខណៈដែលចំនួនគណនីជួញដូរតាមប្រព័ន្ធ MTS ដែលបានបើកថ្មី មានចំណែក៩២% នៃគណនីបើកថ្មីសរុប។

គួររំលឹកផងដែរថា កម្មវិធីឈ្មួញជើងសារមូលបត្រឆ្នើមនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកនូវក្រុមហ៊ុនឈ្មួញជើងសារមូលបត្រឆ្នើមប្រចាំត្រីមាសនីមួយៗ ដែលមានភាពឈានមុខគេក្នុងការផ្តល់សេវាកម្មឈ្មួញជើងសារមូលបត្រសម្រាប់អតិថិជនរបស់ខ្លួន។

**ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

Cambodia Securities Exchange

CSX


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង÷

លោកស្រី **គឹម សុផានីតា** ប្រធាននាយកដ្ឋាន

នាយកដ្ឋានប្រតិបត្តិការទីផ្សារ

អ៊ីម៉ែល÷ sophanita.kim@csx.com.kh